កាលបរិច្ឆេទៈ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៨

# មេរៀនដាំដំណាំបន្លែឪឡឹក

## បច្ចេកទេសនៃការដាំដំណាំបន្លែឪឡឹក

១. ជាដំបូងត្រូវជ្រើសរើសដីទួលសម្រាប់ដាំដំណាំបន្លែឪឡឹក

២. កាប់គាស់ភ្ជួររាស់និងហាលដីឱ្យបាន១សប្តាហ៍ឬលើស១សប្តាហ៍

៣. កាប់ចង្អូរសម្រាប់ដាំឪឡឹកដោយយកជម្រៅ១តឹកកន្លះនិងទទឹងមាត់ចង្អូរ២តឹកកន្លះ។

៤. គម្លាតពីជួរមួយទៅជួរមួយយកប្រវែង១ម៉ែត្រ រីឯបណ្តោយវាអាស្រ័យលើស្ថានភាពដីដែលមាន។

៥. ដាក់ជីធម្មជាតិតាមចង្អូរក្នុង១ម៉ែត្រការប្រើជី៥គីឡូក្រាម

៦. យកគ្រាប់ពូជមកស្រុះ ទឹកក្តៅឧណ្ហៗរយៈពេល១០នាទីបន្ទាប់មកត្រាំទឹកត្រជាក់រយៈពេល៥ម៉ោងនិងដាក់ផ្អាប់បន្តទុកក្នុងទឹកកករយៈពេល៦ម៉ោងទៀត បន្ទាប់ពីនោះយើងអាចយកគ្រាប់ពូជមកដាំបាន។ ក្នុង១រណ្តៅយើងប្រើពូជ៣គ្រាប់។

៧. <u>សូមបញ្ជាក់</u>៖ ការដាំពីគុម្ពមួយទៅគុម្ពមួយយកប្រវែង១ម៉ែត្រ។

៨. ការដាំឪឡឹកប្រើរយៈពេល១ខែកន្លះទើបអាចផ្តល់ផល។

---

រៀបចំដោយ លោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE) និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

៩. ចំណុចសំខាន់គឺតាមដាន ថែទាំ ស្រោចទឹក  ដកស្មៅ និងកំចាត់សត្វល្អិត។ល។

**សូមអរគុណ**

រៀបចំដោយ  លោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE) និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

កាលបរិច្ឆេទៈ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៨

# មេរៀនដំណាំត្រសក់ចំណារ

ត្រសក់ចំណារគឺជាដំណាំដែលគេនិយមដាំ និងនិយមបរិភោគផ្លែខ្ចី។ វាជាប្រភពដែលសម្បូរវីតាមីន និងសម្បូរសារធាតុរ៉ែផ្សេងៗជាច្រើនដូចជា ទឹក ប្រូតេអ៊ីន ប្រេងខ្លាញ់ ថាមពលជាតិដែក និងវីតាមីនសេជាដើម។

## ១.បច្ចេកទេសនៃការដាំដំណាំត្រសក់ចំណារ

### ១.១.ការជ្រើសរើសពូជ

ការជ្រើសរើសពូជជាកត្តាសំខាន់ដំបូងសំរាប់ការដាំដុះកំណត់ទិន្នផល និងតម្រូវការទីផ្សារ។

កត្តាសំខាន់ៗដែលត្រូវកំណត់ជ្រើសរើសពូជមានដូចខាងក្រោម៖

- ពូជមានប្រភពច្បាស់លាស់ (ពូជក្នុងស្រុកឬពូជបង្កាត់)
- ពូជមានអាយុកាលត្រឹមត្រូវ
- ពូជដែលមានដំណុះល្អ៨៥-៩០%
- ពូជសុទ្ធល្អ

រៀបចំដោយ លោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE) និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្រ្តីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

❖ ពូជធន់នឹងអាកាសធាតុ ធន់នឹងសត្វល្អិត និងធន់នឹងជម្ងឺ។ ចំពោះពូជបង្កាត់មិនអាចទុកពូជសម្រាប់ដាំបន្តបានទេ។

## ១.២.ការរៀបចំដី

- ការភ្ជួរដីនិងរាស់ដីឲ្យបាន២ទៅ៣ដង
- ហាលដីឲ្យស្ងួតល្អរយៈពេលពី១០ទៅ១៥ថ្ងៃ
- វាយដីឲ្យម៉ដ្ឋនិងសំអាតស្មៅចេញឲ្យបានស្អាត។

## ១.៣.ការលើករង

➢ យើងអាចលើករងកំពស់ពី១៥ទៅ២៥ស.ម នៅរដូវប្រាំង នៅរដូវវស្សា កំពស់រងពី២៥ទៅ៣០ស.ម និងទទឹងរង១០០ស.ម រីឯបណ្តោយតាមលទ្ធភាពដែលអាចធ្វើបាន។

➢ ដាក់ជីធម្មជាតិពី៥ទៅ៦គីឡូក្រាមក្នុង១ម៉ែត្រការ៉េ ច្របល់ជាមួយដី រួចរាស់លុបឲ្យបានស្មើល្អ។

## ១.៤.របៀបដាំដុះ

### ក.ការដាំត្រាប់ផ្ទាល់

➢ ក្រោយពីលើករងរួចគេជីករណ្តៅជម្រៅពី ២០ទៅ៣០ស.ម

- ក្នុង១រណ្តៅត្រូវដាក់ជីកំប៉ុស្ត៍0.៥-១គ.ក្រ
- ហាលគ្រាប់ពូជរយ:ពេល១ម៉ោងបន្ទាប់មកលាងទឹកសំអាតឲ្យស្អាតរួចត្រាំទឹករយ:ពេលពី៤ទៅ៥ម៉ោង ហើយរុំគ្រាប់ពូជជាមួយនឹងក្រណាត់រួចហើយកប់ដីសើមរយ:ពេលមួយយប់។
- អត្រាគ្រាប់ត្រសក់ដាំពី១ទៅ២គ្រាប់ក្នុង១រណ្តៅ រួចយកកំណាត់ចំបើងខ្លីៗឬជីធម្មជាតិពុកផុយរលួយល្អមករោយគ្របពីលើរណ្តៅ រួចហើយស្រោចទឹកភ្លាមដើម្បីឲ្យគ្រាប់ពូជឆាប់ដុះលូតលាស់រហ័ស។
- គំលាតពីគុម្ពមួយទៅគុម្ពមួយយកពី៣ទៅ៥តឹករាងជា**អក្សរវី**(V) ចន្លោះផ្លូវដើរយក៥តឹក និងទ្រូងដំណាំយក៤ទៅ៥តឹក។

## ៦.ការបណ្តុះកូន

- ជាដំបូងគេត្រូវលាយល្បាយដីសំរាប់បណ្តុះគ្រាប់ពូជដោយប្រចល់ដីខ្សាច់ម៉ដ្ឋដែលបានសំលាប់មេរោគរួចចំនួន៥0% (យកដីខ្សាច់មកគ្របដោយកៅស៊ូប្លាស្ទិកដោយដាក់ហាលថ្ងៃរយ:ពេល២ទៅ៣ថ្ងៃ)និងដីល្បាយដែលមានជីជាតិចំនួន៥0% រួចច្របល់ឲ្យសព្វល្អ ហើយច្រកចូលក្នុងថង់ប្លាស្ទិក កន្ទោង ឬថ្នាល។
- ត្រូវចោះបាតថង់ប្លាស្ទិកឬកន្ទោងនោះ ដើម្បីឲ្យជ្រាបទឹកចេញបានល្អ រួចយកគ្រាប់សាបតែម្តង។

រៀបចំដោយ លោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE) និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

## គ.ការដាំដោយកូន

- របៀបដាំដូចទៅនឹងរបៀបដាំគ្រាប់ផ្ទាល់ខាងលើដែរ
- គេអាចដាំកូនត្រសក់នៅពេលដែលវាមានស្លឹក២ឬ៣សន្លឹក
- ត្រូវដាំនៅពេលល្ងាចត្រជាក់ល្អ
- បន្ទាប់ពីដាំហើយត្រូវយកកំទេចចំបើងស្ងួតៗមករោយលើគល់ដើម្បីរក្សាសំណើម។

## ២.ការថែទាំ

### ២.១.ការជ្រោយដី ពូនគល់ និងការកំចាត់ស្មៅ

ជម្រះស្មៅ ជ្រោយដី ពូនគល់ និងដករំលោះកូនមុនដាក់ជីបំប៉ន។ ត្រូវស្រោចទឹក២ដងក្នុង១ថ្ងៃ នៅពេលព្រឹកនិងពេលល្ងាចជាប្រចាំរហូតដល់ពេលឈប់ប្រមូលផល។

### ២.២.ការដាក់ជី

ប្រើជីកំប៉ុស្ត៍សម្រាប់ទ្រាប់បាតដោយក្នុងមួយរណ្តៅប្រើជីពី0.៥ គីឡូក្រាម ទៅ១គីឡូក្រាម។

### ២.៣.ការស្រោចស្រប់

រៀបចំដោយ លោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE) និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

- ត្រូវស្រោចទឹកជាប្រចាំនៅពេលព្រឹក និងពេលល្ងាច
- ត្រូវរក្សាសំណើមពី ៦០ទៅ៧០% ប្រសិនបើមានសំណើមខ្ពស់ ពេកអាចកើតឡើងនូវពពួកជម្ងឺក្នុងដី។

## ២.៤.ការដាក់ចំណារ

❖ នៅពេលកូនត្រសក់ចាប់ផ្ដើមបោះទង ក្រោយដាំរយៈពេលពី១០ ទៅ១៥ថ្ងៃយើងចាប់ធ្វើចំណារដោយយកមែកឈើរឬកូនឬស្សីមកដោតរួច ចងផ្ដុំគ្នាតាមបណ្ដោយរងដែលមានកំពស់ពី១.៥ទៅ២ម៉ែត្រ។

❖ ពេលត្រសក់បែកខ្នែងក្រោយដាំបាន២០ទៅ២៥ថ្ងៃ យើងត្រូវ ត្រួតពិនិត្យ និងដាក់ចំណារឲ្យត្រសក់ឡើងឱ្យបានល្អ។

## ៣.ការប្រមូលផលនិងការទុកដាក់គ្រាប់ពូជ

## ៣.១.ការប្រមូលផល

យើងអាចប្រមូលផលផ្លែត្រសក់ក្រោយពេលដាំដុះឬមានអាយុដូច ខាងក្រោម៖

- ✓ ពូជស្រាលអាយុ៣៥ទៅ៤០ថ្ងៃ
- ✓ ពូជកណ្ដាលអាយុ ៤០ទៅ៥០ថ្ងៃ

រៀបចំដោយ លោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE) និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

- ✓ ពូជធ្ងន់អាយុ ៥០ទៅ៦០ថ្ងៃ
- ✓ ការប្រមូលផលត្រសក់បើឃើតយ៉ាវបណ្ដាលឲ្យផ្លែត្រសក់ចាស់គ្មានតម្លៃនៅលើទីផ្សារ។

## ៣.២.ការទុកដាក់គ្រាប់ពូជ

ត្រូវជ្រើសរើសផ្លែត្រសក់ណាដែលធំ ទុំល្អ គ្មានជម្ងឺនិងគ្មានសត្វល្អិតបំផ្លាញ។ ក្រោយពីបេះវារួចត្រូវយកវាទុករយៈពេលពី៣ទៅ៥ថ្ងៃ ដើម្បីឲ្យគ្រាប់របេះចេញពីសាច់ ទើបពុះច្របាច់លាងទឹកឲ្យស្អាត និងហាលថ្ងៃឲ្យស្ងួតល្អ រួចច្រកពូជក្នុងដបឬកែវ(ទុក១ភាគ៣នៃដប)គ្របឲ្យជិតទុកនៅកន្លែងដែលមានសុវត្ថិភាព កន្លែងត្រជាក់និងមានខ្យល់ចេញចូលគ្រប់គ្រាន់៕

**សូមអរគុណ**

រៀបចំដោយ  លោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE) និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)